# សេចក្តីសង្ខេប

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផ្តល់អាទិភាពជាចំបងដល់សកម្មភាពដាំដើមឈើ ។ រដ្ឋបាលព្រៃឈើ ដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងគំរោងគ្រាប់ពូជឈើកម្ពុជា បានបង្កើតប្រភពគ្រាប់ពូជឈើជាច្រើននៅក្នុងព្រៃធម្មជាតិនៅពាសពេញផ្ទៃប្រទេសក្នុងគោលបំណងធានានូវការផ្គត់ផ្គង់គ្រាប់ពូជឈើ ដែលមានគុណភាពល្អដល់កម្មវិធីដាំដើមឈើនានា។ នៅពេលដែលមានការដាំឈើជាទ្រង់ទ្រាយតូចៗជាច្រើនត្រូវបានចាប់ផ្តើមឡើងនៅពាសពេញ ផ្ទៃប្រទេសនោះតម្រូវឱ្យមានការរៀបចំផែនការគ្រប់គ្រងរយៈពេលវែងមួយ ។

ផ្នែកទីមួយនៃឯកសារនេះ មានគោលបំណងជួយដល់រដ្ឋបាលព្រៃឈើក្នុងការរៀបចំផែនការការងារដាំឈើ ដែលក្នុងនោះការកំណត់ទីតាំងសមស្របដើម្បីឱ្យការប្រើប្រាស់ថវិកាចំទីតាំងដែលមានអាទិភាពខ្ពស់ ទាំងនៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ ផែនការអភិវឌ្ឍន៍របស់បណ្តាប្រទេសផ្តល់ជំនួយ ក៏ដូចជាវិនិយោគិន និង ស្ថាប័នផ្តល់ជំនួយផ្សេងៗទៀត។ ឯកសារនេះមាន គោលដៅជួយបង្កើនប្រសិទ្ធិភាពក្នុងការងារគ្រប់គ្រងកម្មវិធីដាំដើមឈើ តាមរយៈការលើកទឹកចិត្តឱ្យមានការអនុវត្ត ជាជំហានៗនូវវិធីសាស្ត្រកំណត់ទីតាំងដែលត្រូវដាំឈើ ដោយគិតគូរផងដែរអំពីការចូលរួមរបស់បណ្តាអ្នកពាក់ព័ន្ធនានា ។

សុវត្ថិភាពនៃការកាន់កាប់ដី និងធនធានដែលប្រើប្រាស់ គឺជាតម្រូវការចាំបាច់ក្នុងការជ្រើសរើសទីតាំង ហេតុដូច្នេះហើយជំហាននៃដំណើរការដែលបង្ហាញជូននៅក្នុងគោលការណ៍ណែនាំនេះមានសុពលភាពតែនៅក្នុងតំបន់ទាំងឡាយណាដែលបញ្ហាខាងលើត្រូវបានដោះស្រាយរួចរាល់ឬមិនមានបញ្ហា។ រួមជាមួយនឹងផែនការប្រើប្រាស់ដី គោលការណ៍ណែនាំនេះត្រូវបានរៀបចំធ្វើយ៉ាងណាដើម្បីឱ្យអ្នកប្រើប្រាស់អាចអនុវត្តន៍បានទាំងក្នុងការងារដាំឈើជាចំការ ការស្តារដីព្រៃឈើរេចរិលឡើងវិញ និង ការដាំឈើដោយសហគមន៍ ។

សុវត្ថិភាពនៃការកាន់កាប់ដី និង ការប្រើប្រាស់ធនធានធម្មជាតិគឺជាតំរូវការជាបឋម សំរាប់ការជ្រើសរើសទីតាំងដែលត្រូវដាំឈើ ដូច្នេះដំណើរការនានាដែលបានបង្ហាញនៅក្នុងគោលការណ៍ណែនាំ អាចអនុវត្តបានតែនៅក្នុងតំបន់នោះតែប៉ុណ្ណោះ។ តាមរយៈការធ្វើសមាហរណកម្មទៅក្នុងផែនការប្រើប្រាស់ដីថ្នាក់ខ្ពស់ គោលការណ៍ណែនាំនេះត្រូវបានតាក់តែងឡើងយ៉ាងណាឱ្យអនុវត្តបានទាំងការបង្កើតចំការឈើដាំ ការស្តារដីព្រៃឡើងវិញ សកម្មភាពដាំដើមឈើដោយសហគមន៍ និង សង្គមព្រៃឈើ ។

ដំណើរការនៃការជ្រើសរើសទីតាំងដែលត្រូវដាំឈើត្រូវបានបង្ហាញជូនដោយស៊េរីនៃគំនូសបំព្រួញដោយមានការពន្យល់ ព្រមទាំងឯកសារគាំទ្រមួយចំនួនទៀត។ បណ្តាលក្ខណៈវិនិច្ឆ័យនិងសន្ទស្សន៍នានាដែលទាក់ទងនឹងលក្ខណៈនៃទីកន្លែង កំរិតនៃការខូចខាតធនធានធម្មជាតិ និង អត្រាភាពក្រីក្រត្រូវបានលើកយកមកបង្ហាញ ដើម្បីជាមូលដ្ឋាន

ក្នុងការវាយតម្លៃទីតាំងដែលបំរុងនឹងដាំឈើ មុននឹងឈានដល់ការវាយតម្លៃជាលម្អិតអំពីបញ្ហាសង្គមសេដ្ឋកិច្ច នយោបាយ និងបរិស្ថាន ។

កត្តាជំរុញមួយចំនួនដែលនៅក្រៅវង្វង់នៃគោលការណ៍ណែនាំនេះ ក៏ត្រូវបានកំណត់ឡើងផងដែរ ដូចជាបណ្តាច្បាប់និងលិខិតបទដ្ឋាននានាថវិកា ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ និង ការសិក្សាស្រាវជ្រាវអំពីការងារដាំដើមឈើជាដើម ។ បញ្ហាទាំងអស់នេះ រួមជាមួយនឹងមូលហេតុដែលធ្វើឱ្យព្រៃឈើរេចរិល ត្រូវតែដោះស្រាយឱ្យបានជ្រះស្រលះ ដើម្បីធានាថាការដាំដើមឈើនឹងអាចទទួលបានជោគជ័យ ។

បន្ទាប់ពីបានកំណត់ទីតាំងសមស្របរួចហើយផ្នែកទី ២ គោលការណ៍ណែនាំសំរាប់ការអនុវត្តកម្មវិធីដាំដើមឈើក៏ត្រូវបានរៀបចំចងក្រងឡើងក្នុងគោលបំណងជួយខាងផ្នែកបច្ចេកទេសដល់អ្នកអនុវត្តន៏ការងារនៅលើទីវាលជាក់ស្តែង។ នៅក្នុងផ្នែកទី ២នេះ មានបង្ហាញជូនអំពីវិធីសាស្ត្រនានាដែលសមស្របនឹងកម្មវត្ថុនៃការដាំឈើ។ គោលការណ៍ណែនាំនេះ មានពត៌មានលម្អិតអំពីជំហានចាំបាច់នានាក្នុងការងារគ្រប់គ្រង ការជ្រើសរើសប្រភេទឈើ លទ្ធកម្មគ្រាប់ពូជដោយមានឧទាហរណ៍អំពីការគណនាតម្រូវការគ្រាប់ពូជក្នុងមួយហិកតា ដំណើរការថ្នាលបណ្តុះកូនឈើ ការងារដាំឈើ និង ថែរក្សាចំការឈើដាំ ។

ក្នុងដំណើរការនៃការរៀបចំគោលការណ៍ណែនាំសំរាប់កំណត់ទីតាំង និង អនុវត្តកម្មវិធីដាំដើមឈើនេះ ជំនួបពិភាក្សា ក៏ដូចជាកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងបណ្តាអ្នកពាក់ព័ន្ធក្នុងការងារដាំឈើនានា ត្រូវបានធ្វើឡើងជាបន្តបន្ទាប់។ គោលការណ៍ណែនាំនេះត្រូវបានផ្តើមគំនិតឡើងដោយរដ្ឋបាលព្រៃឈើ ដោយមានកិច្ចសហការជាមួយនឹងគំរោងគ្រាប់ពូជឈើកម្ពុជា និងមានការគាំទ្រផ្នែកថវិកាពីស្ថានទូតរាជរដ្ឋាភិបាលដាណឺម៉ាក្ស ប្រចាំរាជធានីភ្នំពេញតាមរយៈគំរោងគាំទ្រការកសាងគោលនយោបាយវិស័យគ្រាប់ពូជឈើនៅកម្ពុជា ។